ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២២៧ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការរៀបចំនិងការប្រព្រឹត្តទៅនៃបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១២១/០០៣ ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០២១ ស្តីពីការបង្កើតបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១៤អនក្រ.បកចុះថ្ងៃទី០៧ខែកញ្ញា ឆ្នាំ២០១៥ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធនៃគ្រប់ក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៥ អនក្រ.បក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ ស្តីពីការគ្រប់គ្រងថវិកានិងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ._**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា (**ប.ប.ឌ.**)។

## ជំពូកទី២
## រចនាសម្ព័ន្ធ

**មាត្រា២ ._**

**ប.ប.ឌ.** មានរចនាសម្ព័ន្ធដូចតទៅ៖

១- ក្រុមប្រឹក្សាវិទ្យាសាស្ត្រ

២- វិទ្យាស្ថានចំនួន ៣ ថ្នាក់ស្មើអគ្គនាយកដ្ឋាន មានជាអាទិ៍ វិទ្យាស្ថានបច្ចេកវិទ្យាឌីជីថល វិទ្យាស្ថានអភិបាលកិច្ចឌីជីថល និងវិទ្យាស្ថានស្រាវជ្រាវនិងនវានុវត្តន៍ឌីជីថល។ វិទ្យាស្ថានចំណុះ **ប.ប.ឌ.** មានមហាវិទ្យាល័យ សាលា និងមជ្ឈមណ្ឌលដែលមានថ្នាក់ស្មើនាយកដ្ឋាន។

៣- នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

៤- អង្គភាពសវនកម្មផ្ទៃក្នុង។

**ប.ប.ឌ.** មានគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម ជាសេនាធិការលើការងារលទ្ធកម្មសាធារណៈ និងគណៈកម្មការរៀបចំបញ្ជីសារពើភណ្ឌ ជាសេនាធិការលើការងារបញ្ជីសារពើភណ្ឌ ដែលត្រូវបង្កើតដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

**ប.ប.ឌ.** អាចស្នើសុំបង្កើតអង្គភាពចំណុះផ្សេងទៀតដោយអនុក្រឹត្យ តាមការចាំបាច់។

ការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យ និងអង្គភាពនានា ក្រោមឱវាទនាយកដ្ឋាន មហាវិទ្យាល័យ សាលា និងមជ្ឈមណ្ឌល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

អង្គការលេខរបស់ **ប.ប.ឌ.** ជាឧបសម្ព័ន្ធ១ នៃអនុក្រឹត្យនេះ។

**មាត្រា៣ ..**

**ម.ម.ឌ.** អាចមានទីប្រឹក្សាមួយចំនួនតាមការចាំបាច់ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធជាធរមាន។

**ម.ម.ឌ.** មានរូបសញ្ញានិងត្រាដោយឡែករបស់ខ្លួន។

## ជំពូកទី ៣
## ក្រុមប្រឹក្សាវិទ្យាសាស្ត្រ

**មាត្រា៤ ..**

ក្រុមប្រឹក្សាវិទ្យាសាស្ត្រ **ម.ម.ឌ.** ដឹកនាំដោយប្រធាន ០១ (មួយ) រូប និងអមដោយអនុប្រធាននិងសមាជិកផ្សេងទៀតយ៉ាងច្រើន ១០ (ដប់) រូប ដែលជាសាស្ត្រាចារ្យឧត្តមសិក្សា ឬអ្នកស្រាវជ្រាវដែលមានជំនាញលើផ្នែកបច្ចេកវិទ្យា គោលនយោបាយ នីតិសាស្ត្រ គ្រប់គ្រង ហិរញ្ញវត្ថុ សេដ្ឋកិច្ច រដ្ឋបាល ឬទំនាក់ទំនងអន្តរជាតិ និងបុគ្គលឆ្នើមក្នុងវិស័យសាធារណៈ ឬឯកជន ដែលមានជំនាញឌីជីថល។

ប្រធាន អនុប្រធាន និងសមាជិកនៃក្រុមប្រឹក្សាវិទ្យាសាស្ត្រ **ម.ម.ឌ.** ត្រូវតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដែលមានអាណត្តិ ៣ (បី) ឆ្នាំ ហើយអាចត្រូវបានតែងតាំងបន្តនៅពេលចប់អាណត្តិ។

ប្រធាន អនុប្រធាន និងសមាជិកនៃក្រុមប្រឹក្សាវិទ្យាសាស្ត្រ **ម.ម.ឌ.** អាចទទួលបានលាភការ ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗតាមគោលការណ៍កំណត់ដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល **ម.ម.ឌ.**។

**មាត្រា៥ ..**

ក្រុមប្រឹក្សាវិទ្យាសាស្ត្រ **ម.ម.ឌ.** ផ្តួចផ្តើមគំនិតនិង/ឬផ្តល់អនុសាសន៍លើការងារ ដូចខាងក្រោម៖

- រៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រនៃការអប់រំ ការបណ្តុះបណ្តាល ការស្រាវជ្រាវ ការអភិវឌ្ឍ និងនវានុវត្តន៍របស់ **ម.ម.ឌ.**
- រៀបចំនិងដាក់ឱ្យអនុវត្តកម្មវិធីសិក្សា ការស្រាវជ្រាវ ការបោះពុម្ពផ្សាយ និងកម្មវិធីបណ្តុះបណ្តាលពាក់ព័ន្ធនឹងបច្ចេកវិទ្យាឌីជីថលប្រកបដោយគុណភាព
- កំណត់គុណវុឌ្ឍិនិងលក្ខខណ្ឌការងាររបស់សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ គ្រូឧទ្ទេស គ្រូបង្រៀន
- កំណត់គោលការណ៍នៃការផ្តល់សញ្ញាបត្រ និងវិញ្ញាបនបត្រ
- ជំរុញការសិក្សា ស្រាវជ្រាវ ចងក្រង និងផ្សព្វផ្សាយករណីសិក្សា ឧត្តមានុវត្តន៍ និងនវានុវត្តន៍ក្នុងវិស័យឌីជីថល
- វាយតម្លៃលើលទ្ធផលនៃការស្រាវជ្រាវ ការអភិវឌ្ឍ និងនវានុវត្តន៍បច្ចេកវិទ្យាឌីជីថល របស់ **ម.ម.ឌ.**
- សម្របសម្រួលនិងភ្ជាប់ទំនាក់ទំនង **ម.ម.ឌ.** ទៅស្ថាប័នស្រាវជ្រាវ និងផ្នែកឧស្សាហកម្មបច្ចេកវិទ្យា
- វាយតម្លៃទទួលស្គាល់ទេពកោសល្យក្នុងក្របខណ្ឌនៃការបណ្តុះបណ្តាល ការស្រាវជ្រាវ និងនវានុវត្តន៍ឌីជីថលដើម្បីផ្តល់រង្វាន់និងលើកទឹកចិត្ត
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាន **ម.ម.ឌ.** ប្រគល់ជូន។

## ជំពូកទី៤
## វិទ្យាស្ថានបច្ចេកវិទ្យាឌីជីថល

**មាត្រា៦ ._**

វិទ្យាស្ថានបច្ចេកវិទ្យាឌីជីថលមានមហាវិទ្យាល័យវិស្វកម្មឌីជីថល មហាវិទ្យាល័យធុរកិច្ចឌីជីថល និងមជ្ឈមណ្ឌលបច្ចេកវិទ្យាអប់រំ។ វិទ្យាស្ថានបច្ចេកវិទ្យាឌីជីថលមានសិទ្ធិប្រើប្រាស់ត្រារបស់ **ប.ប.ឌ.** សម្រាប់បំពេញភារកិច្ច។

វិទ្យាស្ថានបច្ចេកវិទ្យាឌីជីថល ដឹកនាំដោយប្រធាន ០១ (មួយ)រូប ដែលមានសញ្ញាបត្របណ្ឌិត និងត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី ដោយមានការស្នើពីរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងមានអនុប្រធានមួយចំនួនជាជំនួយការដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ ស្របតាមបទប្បញ្ញត្តិជាធរមាន និងត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ ប្រធាន និងអនុប្រធានត្រូវស្ថិតក្នុងក្របខណ្ឌមុខងារសាធារណៈ។

មហាវិទ្យាល័យវិស្វកម្មឌីជីថល និងមហាវិទ្យាល័យធុរកិច្ចឌីជីថល ដឹកនាំដោយព្រឹទ្ធបុរស ០១ (មួយ) រូប និងអមដោយព្រឹទ្ធបុរសរងមួយចំនួនជាជំនួយការតាមការចាំបាច់ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

មជ្ឈមណ្ឌលបច្ចេកវិទ្យាអប់រំ ដឹកនាំដោយប្រធាន ០១ (មួយ)រូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អង្គការលេខនៃវិទ្យាស្ថានបច្ចេកវិទ្យាឌីជីថល ជាឧបសម្ព័ន្ធ ២ នៃអនុក្រឹត្យនេះ។

**មាត្រា៧ ._**

វិទ្យាស្ថានបច្ចេកវិទ្យាឌីជីថលមានភារកិច្ចដូចតទៅ៖

- ផ្តល់ការអប់រំ និងបណ្តុះបណ្តាលកម្រិតជំនាញវិជ្ជាជីវៈ បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិតលើជំនាញពាក់ព័ន្ធនឹងបច្ចេកវិទ្យានិងធុរកិច្ចឌីជីថល
- បង្កើតមាតិកាអប់រំនិងបណ្តុះបណ្តាលពីចម្ងាយ និងអភិវឌ្ឍបច្ចេកវិទ្យាអប់រំ
- រៀបចំឱ្យមានការប្រឡងវាស់កម្រិតសមត្ថភាពជំនាញពាក់ព័ន្ធនឹងបច្ចេកវិទ្យា និងធុរកិច្ចឌីជីថល
- ចេញសញ្ញាបត្រ ឬវិញ្ញាបនបត្រទទួលស្គាល់កម្រិតសមត្ថភាពជំនាញពាក់ព័ន្ធនឹងបច្ចេកវិទ្យា និងធុរកិច្ចឌីជីថល
- សហការជាមួយស្ថាប័នជាតិនិងអន្តរជាតិ ព្រមទាំងវិស័យឯកជន ដើម្បីពង្រឹងការអប់រំ បណ្តុះបណ្តាល ការស្រាវជ្រាវ និងការផ្ទេរបច្ចេកវិទ្យា
- រៀបចំសិក្ខាសាលា និងកម្មវិធីផ្សព្វផ្សាយលើការអប់រំ និងបណ្តុះបណ្តាលជំនាញពាក់ព័ន្ធនឹងបច្ចេកវិទ្យា និងធុរកិច្ចឌីជីថល
- គ្រប់គ្រងការងាររដ្ឋបាលរបស់វិទ្យាស្ថាន
- រៀបចំផែនការសកម្មភាព ផែនការអភិវឌ្ឍន៍ និងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់វិទ្យាស្ថាន
- ចូលរួមរៀបចំផែនការសកម្មភាព ផែនការអភិវឌ្ឍន៍ និងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់ **ប.ប.ឌ.**
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាន **ប.ប.ឌ.** ប្រគល់ជូន។

**មាត្រា៨ .-**

មហាវិទ្យាល័យវិស្វកម្មឌីជីថលមានភារកិច្ចដូចតទៅ៖

- ផ្តល់ការអប់រំនិងការបណ្តុះបណ្តាលកម្រិតជំនាញវិជ្ជាជីវៈ បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិតលើជំនាញវិស្វកម្មឌីជីថល
- អភិវឌ្ឍនិងរៀបចំមុខវិជ្ជាបង្រៀន ជ្រើសរើសគ្រូបង្រៀន និងកម្មវិធីសិក្សាលើជំនាញវិស្វកម្មឌីជីថល
- សហការជាមួយស្ថាប័នជាតិ និងអន្តរជាតិ ព្រមទាំងវិស័យឯកជន ដើម្បីកែលម្អកម្មវិធីសិក្សាជំនាញវិស្វកម្មឌីជីថល
- សិក្សាស្រាវជ្រាវពីតម្រូវការទីផ្សារការងារជំនាញវិស្វកម្មឌីជីថល
- ចូលរួមរៀបចំផែនការ និងពង្រីកការបណ្តុះបណ្តាលជំនាញវិស្វកម្មឌីជីថល
- រៀបចំស្នើនិងអនុវត្តគម្រោងពាក់ព័ន្ធនឹងការអប់រំនិងបណ្តុះបណ្តាលផ្នែកវិស្វកម្មឌីជីថល
- រៀបចំសិក្ខាសាលា និងកម្មវិធីផ្សព្វផ្សាយពាក់ព័ន្ធនឹងការអប់រំនិងបណ្តុះបណ្តាលផ្នែកវិស្វកម្មឌីជីថល
- រៀបចំផែនការសកម្មភាព ផែនការអភិវឌ្ឍន៍ និងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់មហាវិទ្យាល័យ
- ចូលរួមរៀបចំផែនការសកម្មភាព ផែនការអភិវឌ្ឍន៍ និងគម្រោងផែនការថវិកាប្រចាំឆ្នាំ របស់វិទ្យាស្ថាន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានវិទ្យាស្ថានបច្ចេកវិទ្យាឌីជីថលប្រគល់ជូន។

**មាត្រា៩ .-**

មហាវិទ្យាល័យធុរកិច្ចឌីជីថលមានភារកិច្ចដូចតទៅ៖

- ផ្តល់ការអប់រំនិងការបណ្តុះបណ្តាលកម្រិតជំនាញវិជ្ជាជីវៈ បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិតលើជំនាញធុរកិច្ចឌីជីថល
- អភិវឌ្ឍនិងរៀបចំមុខវិជ្ជាបង្រៀន ជ្រើសរើសគ្រូបង្រៀន និងកម្មវិធីសិក្សាលើជំនាញធុរកិច្ចឌីជីថល
- សហការជាមួយស្ថាប័នជាតិ និងអន្តរជាតិ ព្រមទាំងវិស័យឯកជន ដើម្បីកែលម្អកម្មវិធីសិក្សាជំនាញធុរកិច្ចឌីជីថល
- សិក្សាស្រាវជ្រាវពីតម្រូវការទីផ្សារការងារជំនាញធុរកិច្ចឌីជីថល
- ចូលរួមរៀបចំផែនការ និងពង្រីកការបណ្តុះបណ្តាលជំនាញធុរកិច្ចឌីជីថល
- រៀបចំស្នើនិងអនុវត្តគម្រោងពាក់ព័ន្ធនឹងការអប់រំនិងបណ្តុះបណ្តាលផ្នែកធុរកិច្ចឌីជីថល
- រៀបចំសិក្ខាសាលា និងកម្មវិធីផ្សព្វផ្សាយពាក់ព័ន្ធនឹងការអប់រំនិងបណ្តុះបណ្តាលផ្នែកធុរកិច្ចឌីជីថល
- រៀបចំផែនការសកម្មភាព ផែនការអភិវឌ្ឍន៍ និងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់មហាវិទ្យាល័យ
- ចូលរួមរៀបចំផែនការសកម្មភាព ផែនការអភិវឌ្ឍន៍ និងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់វិទ្យាស្ថាន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានវិទ្យាស្ថានបច្ចេកវិទ្យាឌីជីថលប្រគល់ជូន។

**មាត្រា១០.-**

មជ្ឈមណ្ឌលបច្ចេកវិទ្យាអប់រំមានភារកិច្ចដូចតទៅៈ

- សិក្សាស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាសម្រាប់គាំទ្រដល់ការអប់រំនិងបណ្តុះបណ្តាល
- គ្រប់គ្រង ថែទាំ និងធ្វើឱ្យប្រសើរឡើងប្រព័ន្ធអប់រំពីចម្ងាយ ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យា និងបណ្ណាល័យក្នុង **ប.ប.ឌ.**
- ថែទាំមន្ទីរពិសោធន៍ ក្នុង **ប.ប.ឌ.**
- ផ្តល់សេវាប្រឹក្សានិងអភិវឌ្ឍមាតិកាឌីជីថលសម្រាប់ការអប់រំពីចម្ងាយ
- សហការជាមួយស្ថាប័នជាតិ និងអន្តរជាតិ ព្រមទាំងវិស័យឯកជន លើការអភិវឌ្ឍបច្ចេកវិទ្យាអប់រំ និងការផ្តល់ការអប់រំពីចម្ងាយ
- ពង្រឹងនិងអភិវឌ្ឍសមត្ថភាពសាស្ត្រាចារ្យនិងអ្នកជំនាញរបស់ **ប.ប.ឌ.** ដើម្បីធ្វើឱ្យគុណភាពអប់រំពីចម្ងាយកាន់តែល្អប្រសើរ
- រៀបចំស្នើនិងអនុវត្តគម្រោងពាក់ព័ន្ធនឹងការអប់រំពីចម្ងាយ
- រៀបចំសិក្ខាសាលានិងកម្មវិធីផ្សព្វផ្សាយពាក់ព័ន្ធនឹងការអប់រំពីចម្ងាយ
- រៀបចំផែនការសកម្មភាព ផែនការអភិវឌ្ឍន៍ និងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់មជ្ឈមណ្ឌល
- ចូលរួមរៀបចំផែនការសកម្មភាព ផែនការអភិវឌ្ឍន៍ និងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់វិទ្យាស្ថាន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានវិទ្យាស្ថានបច្ចេកវិទ្យាឌីជីថលប្រគល់ជូន។

## ជំពូកទី៥
## វិទ្យាស្ថានអភិបាលកិច្ចឌីជីថល

**មាត្រា១១.-**

វិទ្យាស្ថានអភិបាលកិច្ចឌីជីថលមានសាលាអភិបាលកិច្ចឌីជីថល និងមជ្ឈមណ្ឌលជំរុញអភិបាលកិច្ចនិងបច្ចេកវិទ្យាឌីជីថល។ វិទ្យាស្ថានអភិបាលកិច្ចឌីជីថលមានសិទ្ធិប្រើប្រាស់ត្រារបស់ **ប.ប.ឌ.** សម្រាប់បំពេញភារកិច្ច។

វិទ្យាស្ថានអភិបាលកិច្ចឌីជីថល ដឹកនាំដោយប្រធាន ០១ (មួយ)រូប ដែលមានសញ្ញាបត្របណ្ឌិតនិងត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី ដោយមានការស្នើពីរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងមានអនុប្រធានមួយចំនួនជាជំនួយការដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅស្របតាមបទប្បញ្ញត្តិជាធរមាន និងត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ ប្រធាន និងអនុប្រធានត្រូវស្ថិតក្នុងក្របខណ្ឌមុខងារសាធារណៈ។

សាលាអភិបាលកិច្ចឌីជីថល ដឹកនាំដោយនាយក ០១ (មួយ)រូប និងអមដោយនាយករងមួយចំនួនជាជំនួយការតាមការចាំបាច់ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

មជ្ឈមណ្ឌលជំរុញអភិបាលកិច្ច និងបច្ចេកវិទ្យាឌីជីថល ដឹកនាំដោយប្រធាន ០១ (មួយ)រូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អង្គការលេខនៃវិទ្យាស្ថានអភិបាលកិច្ចឌីជីថល ជាឧបសម្ព័ន្ធ ៣ នៃអនុក្រឹត្យនេះ។

**មាត្រា១២ ._**

វិទ្យាស្ថានអភិបាលកិច្ចឌីជីថលមានភារកិច្ចដូចតទៅ៖

- បណ្តុះបណ្តាលជំនាញបច្ចេកទេស និងភាពជាអ្នកដឹកនាំឌីជីថលតាមរយៈវគ្គបណ្តុះបណ្តាល និងវិក្រឹត្យការសម្រាប់មន្ត្រីរាជការនិងបុគ្គលិកក្រសួងស្ថាប័ននានារបស់រដ្ឋ
- សិក្សាស្រាវជ្រាវលើគោលនយោបាយអភិបាលកិច្ចឌីជីថលនិងរដ្ឋាភិបាលឌីជីថល
- ផ្តល់សេវាប្រឹក្សាយោបល់ និងជំរុញការចាប់យកការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ក្នុងក្រសួងស្ថាប័ននានារបស់រដ្ឋ
- រៀបចំការប្រឡងវាស់កម្រិតសមត្ថភាព និងចេញវិញ្ញាបនបត្រទទួលស្គាល់ ជំនាញបច្ចេកទេស និងភាពជាអ្នកដឹកនាំឌីជីថលសម្រាប់មន្ត្រីរាជការ និងបុគ្គលិកក្រសួងស្ថាប័ននានារបស់រដ្ឋ
- សហការជាមួយក្រសួង ស្ថាប័នជាតិ និងអន្តរជាតិនានា ព្រមទាំងវិស័យឯកជន ដើម្បីពង្រឹងការបណ្តុះបណ្តាល ការស្រាវជ្រាវ និងការផ្ទេរបច្ចេកវិទ្យា គាំទ្រដល់អភិបាលកិច្ចឌីជីថលនិងរដ្ឋាភិបាលឌីជីថល
- រៀបចំសិក្ខាសាលា និងកម្មវិធីផ្សព្វផ្សាយលើការបណ្តុះបណ្តាល ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងការសិក្សាស្រាវជ្រាវគោលនយោបាយអភិបាលកិច្ចឌីជីថល និងរដ្ឋាភិបាលឌីជីថល
- គ្រប់គ្រងការងាររដ្ឋបាលរបស់វិទ្យាស្ថាន
- រៀបចំផែនការសកម្មភាព ផែនការអភិវឌ្ឍន៍ និងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់វិទ្យាស្ថាន
- ចូលរួមរៀបចំផែនការសកម្មភាព ផែនការអភិវឌ្ឍន៍ និងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់ **ម.ប.ឌ.**
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាន **ម.ប.ឌ.** ប្រគល់ជូន។

**មាត្រា១៣ ._**

សាលាអភិបាលកិច្ចឌីជីថលមានភារកិច្ចដូចតទៅ៖

- រៀបចំមុខវិជ្ជាបង្រៀន ជ្រើសរើសគ្រូបង្រៀន និងកម្មវិធីសិក្សាលើជំនាញអភិបាលកិច្ចឌីជីថល
- ផ្តល់ការបណ្តុះបណ្តាលអក្ខរកម្មឌីជីថល ជំនាញបច្ចេកទេស និងភាពជាអ្នកដឹកនាំឌីជីថលសម្រាប់មន្ត្រីរាជការនិងបុគ្គលិកក្រសួងស្ថាប័ននានារបស់រដ្ឋ
- សហការសិក្សាស្រាវជ្រាវបច្ចេកវិទ្យាឌីជីថល ជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីដាក់បញ្ចូលក្នុងកម្មវិធីសិក្សាជំនាញអភិបាលកិច្ចឌីជីថល
- ចូលរួមរៀបចំផែនការនិងពង្រីកការបណ្តុះបណ្តាលជំនាញអភិបាលកិច្ចឌីជីថលទូទាំងប្រទេស
- សហការជាមួយក្រសួង ស្ថាប័នជាតិ និងអន្តរជាតិ ព្រមទាំងវិស័យឯកជន ដើម្បីពង្រឹងការបណ្តុះបណ្តាលនិងការប្រឹក្សាយោបល់លើជំនាញអភិបាលកិច្ចឌីជីថល
- រៀបចំផែនការសកម្មភាព ផែនការអភិវឌ្ឍន៍ និងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់សាលា
- ចូលរួមរៀបចំផែនការសកម្មភាព ផែនការអភិវឌ្ឍន៍ និងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់វិទ្យាស្ថាន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានវិទ្យាស្ថានអភិបាលកិច្ចឌីជីថលប្រគល់ជូន។

**មាត្រា១៤ ._**

មជ្ឈមណ្ឌលជំរុញអភិបាលកិច្ចនិងបច្ចេកវិទ្យាឌីជីថលមានភារកិច្ចដូចតទៅៈ

- សិក្សាស្រាវជ្រាវលើគោលនយោបាយអភិបាលកិច្ចឌីជីថល និងរដ្ឋាភិបាលឌីជីថល
- អភិវឌ្ឍដំណោះស្រាយបច្ចេកវិទ្យាឌីជីថល ដើម្បីប្រើប្រាស់ក្នុងរាជរដ្ឋាភិបាលនិងស្ថាប័នរដ្ឋនានា
- ផ្តល់សេវាប្រឹក្សាយោបល់លើការរៀបចំគោលនយោបាយ និងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដើម្បីគាំទ្រដល់ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល
- ជំរុញការចាប់យក និងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងស្ថាប័នរដ្ឋនានា
- សហការជាមួយស្ថាប័នជាតិ និងអន្តរជាតិ ព្រមទាំងវិស័យឯកជន ដើម្បីពង្រឹងការសិក្សាស្រាវជ្រាវគោលនយោបាយ ប្រឹក្សាយោបល់ លើដំណោះស្រាយបច្ចេកវិទ្យាគាំទ្រដល់ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល
- រៀបចំផែនការសកម្មភាព ផែនការអភិវឌ្ឍន៍ និងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់មជ្ឈមណ្ឌល
- ចូលរួមរៀបចំផែនការសកម្មភាព ផែនការអភិវឌ្ឍន៍ និងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់វិទ្យាស្ថាន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានវិទ្យាស្ថានអភិបាលកិច្ចឌីជីថលប្រគល់ជូន។

## ជំពូកទី៦
## វិទ្យាស្ថានស្រាវជ្រាវនិងនវានុវត្តន៍ឌីជីថល

**មាត្រា១៥ ._**

វិទ្យាស្ថានស្រាវជ្រាវនិងនវានុវត្តន៍ឌីជីថលមានមជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យាឌីជីថល មជ្ឈមណ្ឌលនវានុវត្តន៍ឌីជីថល និងមជ្ឈមណ្ឌលស្រាវជ្រាវគោលនយោបាយឌីជីថល។

វិទ្យាស្ថានស្រាវជ្រាវនិងនវានុវត្តន៍ឌីជីថល ដឹកនាំដោយប្រធាន ០១ (មួយ)រូប ដែលមានសញ្ញាបត្របណ្ឌិត និងត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី ដោយមានការស្នើពីរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងមានអនុប្រធានមួយចំនួនជាជំនួយការដែលមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅស្របតាមបទប្បញ្ញត្តិជាធរមាន និងត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ ប្រធាន និងអនុប្រធានត្រូវស្ថិតក្នុងក្របខណ្ឌមុខងារសាធារណៈ។

មជ្ឈមណ្ឌលនីមួយៗចំណុះវិទ្យាស្ថានស្រាវជ្រាវនិងនវានុវត្តន៍ឌីជីថល ដឹកនាំដោយប្រធាន ០១ (មួយ)រូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

អង្គការលេខនៃវិទ្យាស្ថានស្រាវជ្រាវនិងនវានុវត្តន៍ឌីជីថល ជាឧបសម្ព័ន្ធ៤ នៃអនុក្រឹត្យនេះ។

**មាត្រា១៦ ._**

វិទ្យាស្ថានស្រាវជ្រាវនិងនវានុវត្តន៍ឌីជីថលមានភារកិច្ចដូចតទៅៈ

- សិក្សាស្រាវជ្រាវ អភិវឌ្ឍ និងផ្ទេរបច្ចេកវិទ្យាក្នុងវិស័យឌីជីថល
- សិក្សាស្រាវជ្រាវ លើគោលនយោបាយអភិវឌ្ឍន៍វិស័យឌីជីថល
- សិក្សាស្រាវជ្រាវ និងវាយតម្លៃលើផលប៉ះពាល់នៃបច្ចេកវិទ្យាឌីជីថលលើសេដ្ឋកិច្ច និងសង្គម
- ជំរុញសហគ្រិនភាពនិងនវានុវត្តន៍ឌីជីថល និងកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នជាតិ និងអន្តរជាតិព្រមទាំង វិស័យឯកជន ដើម្បីចូលរួមលើកកម្ពស់ប្រព័ន្ធនវានុវត្តន៍ជាតិ

- ផ្ដល់ការលើកទឹកចិត្ត ការបណ្ដុះបណ្ដាល និងការគាំទ្រផ្នែកបច្ចេកទេសដល់ការបង្កើតធុរកិច្ចថ្មីឌីជីថល និងជំរុញការចាប់យក និងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងដំណើរការអាជីវកម្ម និងផលិតកម្មរបស់សហគ្រាស
- សិក្សានិងស្រាវជ្រាវលើស្តង់ដារបច្ចេកទេសក្នុងវិស័យឌីជីថល
- ផ្ដល់ការប្រឹក្សាយោបល់លើការស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកវិទ្យា និងគោលនយោបាយក្នុងវិស័យឌីជីថល
- ផ្ដល់លិខិតបញ្ជាក់ការវាយតម្លៃបច្ចេកទេសលើប្រព័ន្ធឌីជីថល
- បោះពុម្ពផ្សាយអត្ថបទសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងបច្ចេកវិទ្យាឌីជីថល
- ជំរុញ និងគាំទ្រដល់ការការពារកម្មសិទ្ធិបញ្ញាលើរាល់ស្នាដៃស្រាវជ្រាវ អភិវឌ្ឍន៍ និងនវានុវត្តន៍របស់វិទ្យាស្ថាន
- រៀបចំកម្មវិធីវាយតម្លៃកម្រិតសមត្ថភាពស្រាវជ្រាវនិងទេពកោសល្យជំនាញឌីជីថល
- លើកសំណើផ្ដល់ការទទួលស្គាល់កម្រិតសមត្ថភាពស្រាវជ្រាវនិងទេពកោសល្យជំនាញឌីជីថល
- គ្រប់គ្រងការងាររដ្ឋបាលរបស់វិទ្យាស្ថាន
- រៀបចំផែនការសកម្មភាព ផែនការអភិវឌ្ឍន៍ និងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់វិទ្យាស្ថាន
- ចូលរួមរៀបចំផែនការសកម្មភាពប្រចាំឆ្នាំរបស់ **ប.ប.ឌ.**
- ចូលរួមរៀបចំផែនការគោលនយោបាយនិងយុទ្ធសាស្ត្ររបស់ **ប.ប.ឌ.**
- ធ្វើរបាយការណ៍ស្ដីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាន **ប.ប.ឌ.** ប្រគល់ជូន។

**មាត្រា១៧ .-**

មជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យាឌីជីថលមានភារកិច្ចដូចខាងក្រោមតទៅ៖

- សិក្សា ស្រាវជ្រាវ និងអភិវឌ្ឍបច្ចេកវិទ្យាឌីជីថល ដើម្បីចូលរួមជំរុញការអភិវឌ្ឍវិស័យឌីជីថល
- រៀបចំសិក្ខាសាលា ឬកម្មវិធីផ្សព្វផ្សាយស្ដីពីការស្រាវជ្រាវនិងអភិវឌ្ឍន៍ក្នុងវិស័យឌីជីថល
- រៀបចំកម្មវិធីវាស់ស្ទង់សមត្ថភាពជំនាញអ្នកស្រាវជ្រាវក្នុងវិស័យឌីជីថល
- សិក្សានិងស្រាវជ្រាវលើស្តង់ដារបច្ចេកទេសក្នុងវិស័យឌីជីថល
- ផ្ដល់ការប្រឹក្សាលើការងារស្រាវជ្រាវនិងអភិវឌ្ឍន៍ ព្រមទាំងសេវាពិសោធន៍ឌីជីថល
- រៀបចំស្នើនិងអនុវត្តគម្រោងស្រាវជ្រាវ អភិវឌ្ឍ និងផ្ទេរបច្ចេកវិទ្យាឌីជីថលដោយសហការជាមួយស្ថាប័នជាតិនិងអន្តរជាតិនានា ព្រមទាំងវិស័យឯកជន លើវិស័យឌីជីថល
- រៀបចំឱ្យមានការប្រកួតប្រជែងសមត្ថភាពពាក់ព័ន្ធនឹងការស្រាវជ្រាវនិងអភិវឌ្ឍន៍
- គាំទ្រ លើកទឹកចិត្ត និងឧបត្ថម្ភចំពោះកិច្ចការស្រាវជ្រាវនិងអភិវឌ្ឍន៍នានាក្នុងវិស័យឌីជីថល
- រៀបចំផែនការសកម្មភាព ផែនការអភិវឌ្ឍន៍ និងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់មជ្ឈមណ្ឌល
- ចូលរួមរៀបចំផែនការសកម្មភាព ផែនការអភិវឌ្ឍន៍ និងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់វិទ្យាស្ថាន
- ធ្វើរបាយការណ៍ស្ដីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានវិទ្យាស្ថានស្រាវជ្រាវនិងនវានុវត្តន៍ឌីជីថលប្រគល់ជូន។

**មាត្រា១៨ ._**

មជ្ឈមណ្ឌលនវានុវត្តន៍ឌីជីថលមានភារកិច្ចដូចតទៅ៖

- ជំរុញនវានុវត្តន៍ និងការបង្កើតធុរកិច្ចឌីជីថល
- ចូលរួមអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីនៃធុរកិច្ចបែបថ្មីដែលប្រើបច្ចេកវិទ្យាឌីជីថល
- ផ្តល់ការប្រឹក្សាយោបល់ ការបណ្តុះបណ្តាល និងការគាំទ្របច្ចេកទេសលើការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដល់វិស័យឯកជន
- ភ្ជាប់ទំនាក់ទំនងរវាងគ្រឹះស្ថានអប់រំ ឧស្សាហកម្ម និងក្រសួង ស្ថាប័នជាតិ
- រៀបចំសិក្ខាសាលា កម្មវិធីប្រកួតប្រជែង និងកម្មវិធីផ្សេងៗទៀតដើម្បីលើកកម្ពស់សហគ្រិនភាពនិងនវានុវត្តន៍វិស័យឌីជីថល
- រៀបចំផែនការសកម្មភាព ផែនការអភិវឌ្ឍន៍ និងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់មជ្ឈមណ្ឌល
- ចូលរួមរៀបចំផែនការសកម្មភាព ផែនការអភិវឌ្ឍន៍ និងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់វិទ្យាស្ថាន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានវិទ្យាស្ថានស្រាវជ្រាវនិងនវានុវត្តន៍ឌីជីថលប្រគល់ជូន។

**មាត្រា១៩ ._**

មជ្ឈមណ្ឌលស្រាវជ្រាវគោលនយោបាយឌីជីថលមានភារកិច្ចដូចតទៅ៖

- សិក្សាស្រាវជ្រាវលើគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យឌីជីថល
- សិក្សាស្រាវជ្រាវ និងវាយតម្លៃលើផលប៉ះពាល់នៃបម្រើបម្រាស់បច្ចេកវិទ្យាឌីជីថលលើនយោបាយ សេដ្ឋកិច្ច និងសង្គម
- រៀបចំនិងបោះពុម្ពផ្សាយអត្ថបទសិក្សាស្រាវជ្រាវពាក់ព័ន្ធនឹងគោលនយោបាយអភិវឌ្ឍវិស័យឌីជីថល
- ផ្តល់ការប្រឹក្សាលើការសិក្សាស្រាវជ្រាវ ការរៀបចំ ការតាមដាននិងវាយតម្លៃលើគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីពាក់ព័ន្ធនឹងវិស័យឌីជីថល
- រៀបចំសិក្ខាសាលា កម្មវិធីផ្សព្វផ្សាយស្តីពីគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យឌីជីថល
- រៀបចំផែនការសកម្មភាព ផែនការអភិវឌ្ឍន៍ និងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់មជ្ឈមណ្ឌល
- ចូលរួមរៀបចំផែនការសកម្មភាព ផែនការអភិវឌ្ឍន៍ និងគម្រោងផែនការថវិកាប្រចាំឆ្នាំរបស់វិទ្យាស្ថាន
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធានវិទ្យាស្ថានស្រាវជ្រាវនិងនវានុវត្តន៍ឌីជីថលប្រគល់ជូន។

## ជំពូកទី៧

## នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ

**មាត្រា២០ ._**

នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុនៃ **ប.ប.ឌ.** ដឹកនាំដោយប្រធាន ០១ (មួយ) រូប និងអមដោយអនុប្រធានមួយចំនួនជាជំនួយការតាមការចាំបាច់ ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត។

**មាត្រា២១ ._**

នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុមានតួនាទីភារកិច្ចដូចតទៅ៖

- គ្រប់គ្រងកិច្ចការរដ្ឋបាលនិងបុគ្គលិក
- រៀបចំផែនការការងាររបស់នាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុនិងរបស់ **ប.ប.ឧ.**
- ផ្គត់ផ្គង់និងគ្រប់គ្រងរាល់សម្ភារៈបរិក្ខារ
- រៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ **ប.ប.ឧ.**
- គ្រប់គ្រងការប្រមូលចំណូល និងទូទាត់ចំណាយរបស់ **ប.ប.ឧ.**
- កាន់កាប់បញ្ជីគណនេយ្យ និងរក្សាទុកលិខិតយុត្តិការច្បាប់ដើម
- រៀបចំនិងគ្រប់គ្រងផែនការថវិការបស់ **ប.ប.ឧ.**
- រៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ **ប.ប.ឧ.** ស្របតាមគោលនយោបាយយុទ្ធសាស្ត្រដែលក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានកំណត់ និងផែនការសកម្មភាពរបស់ **ប.ប.ឧ.** ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល
- រៀបចំផែនការអភិវឌ្ឍន៍ គម្រោងថវិកាប្រចាំឆ្នាំ និងគម្រោងវិនិយោគរបស់ **ប.ប.ឧ.**
- ធ្វើទំនាក់ទំនងជាមួយក្រសួងអាណាព្យាបាលទាំងពីរពាក់ព័ន្ធនឹងការរៀបចំការអនុវត្ត និងការត្រួតពិនិត្យថវិការបស់ **ប.ប.ឧ.**
- គ្រប់គ្រង និងចាត់ចែងការអនុវត្តថវិកា ស្របតាមគោលការណ៍ហិរញ្ញវត្ថុជាធរមាន
- តាមដានលទ្ធផលនៃការអនុវត្តថវិកា
- សម្របសម្រួលក្នុងនាមជាសេនាធិការរបស់ប្រធាន **ប.ប.ឧ** សម្រាប់ការតាមដាននិងការត្រួតពិនិត្យធ្វើអធិការកិច្ច និងសវនកម្ម
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុ របាយការណ៍អនុវត្ត និងរបាយការណ៍សមិទ្ធកម្មរបស់ ប.ប.ឧ ប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងប្រចាំឆ្នាំជូនប្រធានក្រុមប្រឹក្សាភិបាល និងជូនរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សហការនិងសម្របសម្រួលជាមួយអង្គភាពពាក់ព័ន្ធក្នុងការរៀបចំផែនការសកម្មភាពនិងផែនការយុទ្ធសាស្ត្ររបស់ **ប.ប.ឧ.**
- អនុវត្តភារកិច្ចផ្សេងៗទៀតដែលប្រធាន **ប.ប.ឧ.** ប្រគល់ជូន។

## ជំពូកទី៨
## អង្គភាពសវនកម្មផ្ទៃក្នុង

**មាត្រា២២ ._**

អង្គភាពសវនកម្មផ្ទៃក្នុង ត្រូវបង្កើត តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ច ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

អង្គភាពសវនកម្មផ្ទៃក្នុង ទទួលបន្ទុកអនុវត្តភារកិច្ចតាមខ្លឹមសារនៃអនុក្រឹត្យលេខ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុង នៅតាមបណ្តាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ និងអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត។

## ជំពូកទី៩
## អវសានប្បញ្ញត្តិ

**មាត្រា២៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ១១ កើត ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

**ជា វ៉ាន់ដេត**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ២២៧ អនក្រ.បក ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០២១ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា

**អង្គការលេខរបស់បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា**



ឧបសម្ព័ន្ធ២ នៃអនុក្រឹត្យលេខ២៦៣ អនក.បក ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា

## អង្គការលេខរបស់វិទ្យាស្ថានបច្ចេកវិទ្យាឌីជីថល



# អង្គការលេខរបស់វិទ្យាស្ថានអភិបាលកិច្ចឌីជីថល



ឧបសម្ព័ន្ធ៤ នៃអនុក្រឹត្យលេខ២២៣ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០២១ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា

## អង្គការលេខរបស់វិទ្យាស្ថានស្រាវជ្រាវនិងនវានុវត្តន៍ឌីជីថល

